

# មិត្តវ័យក្មេងជាទីស្រឡាញ់របស់យើងអើយ

យើងសង្ឃឹមថាប្អូនៗនឹងរីករាយនឹងលេខពិសេសនៃទស្សនាវដ្ដី *ប្រិយមិត្ត* នេះ ។ ពេញមួយច្បាប់នេះគឺផ្ដោតទៅលើពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ។

ប្រសិនបើប្អូនៗទើបតែបានទទួលបុណ្យជ្រមុជទឹក នោះយើងសូមស្វាគមន៍ប្អូនៗជាសមាជិកថ្មីនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ !

នៅពេលប្អូនៗទទួលពិធីបុណ្យជ្រមុជទឹក នោះប្អូនៗកំពុងធ្វើតាមគំរូនៃព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវគ្រីស្ទ ។ ប្អូនៗសន្យាថានឹងចងចាំព្រះអង្គសង្គ្រោះ ហើយរក្សាបញ្ញត្តិរបស់ទ្រង់ ។ ការសន្យាទាំងនេះហៅថាសេចក្ដីសញ្ញា ។ នៅពេលប្អូនៗបានទទួលពិធីបញ្ជាក់ នោះគឺប្អូនៗទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធអាចលួងលោម ដឹកនាំ និងបំផុសគំនិតប្អូនៗពេញមួយជីវិត ។

ប្រសិនបើប្អូនៗបានទទួលពិធីបុណ្យជ្រមុជទឹករួចហើយ យើងសូមលើកទឹកចិត្តប្អូនៗឲ្យចងចាំសេចក្ដីសញ្ញាដែលប្អូនៗបានធ្វើនៅឯពិធីបុណ្យជ្រមុជទឹក ហើយព្យាយាមធ្វើតាមព្រះយេស៊ូវជារៀងរាល់ថ្ងៃ ។

ប្រសិនបើប្អូនៗមិនទាន់បានទទួលពិធីបុណ្យជ្រមុជទឹកនៅឡើយទេ យើងសង្ឃឹមថាប្អូនៗនឹងត្រៀមខ្លួនដោយរៀនបន្ថែមទៀតអំពីជំហានដ៏សំខាន់នេះ ។

យើងមានមោទនភាពយ៉ាងខ្លាំងចំពោះប្អូនម្នាក់ៗ ។ យើងដឹងថា ព្រះវរបិតាសួគ៌កំពុងទតមើលប្អូនៗ ។ ទ្រង់ស្រឡាញ់ប្អូនៗខ្លាំងណាស់ ហើយពួកយើងក៏ដូច្នោះដែរ ។

គណៈប្រធានទីមួយ

ដើម្បីបញ្ជាទិញ កូនសៀវភៅនៃពិធីបុណ្យជ្រមុជទឹកនេះបន្ថែមទៀត នោះសូមមើលនៅក្របក្រោយសៀវភៅនេះ